ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៩. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ។ ក្រុមប្រឹក្សាសកម្មភាពជនពិការ ដែលសរសេរជាអក្សរកាត់ថា **ក.ស.ជ.** ជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាព។

## ជំពូកទី២
## សមាសភាពរបស់ ក.ស.ជ.

**មាត្រា២.-**

សមាសភាព **ក.ស.ជ.** មានដូចតទៅ ៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ១ រូប | អនុប្រធាន |
| - តំណាងអង្គការជនពិការដែលជាជនពិការ | ១ រូប | អនុប្រធាន |
| - អគ្គលេខាធិការរងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងផែនការ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ១ រូប | សមាជិក |

- តំណាងកាកបាទក្រហមកម្ពុជា ១ រូប សមាជិក
- អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១ រូប សមាជិក
- អគ្គលេខាធិការរងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ១ រូប សមាជិក
- តំណាងអង្គការជនពិការដែលជាជនពិការ (បុរស ២ រូប និង ស្ត្រី ២ រូប) ៤ រូប សមាជិក
- តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យពិការភាព ១ រូប សមាជិក
- តំណាងអង្គការនិយោជក ១ រូប សមាជិក
- លេខាធិការនៃ **ក.ស.ជ.** លេខាធិការ។

សមាសភាពជាក់ស្ដែងរបស់ **ក.ស.ជ.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទី និងភារកិច្ចរបស់ ក.ស.ជ.

**មាត្រា៣.-**

**ក.ស.ជ.** មានភារកិច្ចដូចខាងក្រោម ៖

- ផ្ដល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្ដារលទ្ធភាពពលកម្ម
- ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធ-សាស្ត្រ ដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្ដារលទ្ធភាពពលកម្ម
- ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្ដារលទ្ធភាពពលកម្ម
- លើកសេចក្ដីស្នើកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្មគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗដែលពាក់ព័ន្ធនឹងបញ្ហាពិការភាព
- តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព
- ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្ដូរបទពិសោធ កៀរគរ ប្រភពធនធានទាំងក្នុង និងក្រៅប្រទេស។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ស.ជ.

**មាត្រា៤.-**

**ក.ស.ជ.** ត្រូវធ្វើការប្រជុំយ៉ាងតិច ២ (ពីរ) ដង ក្នុងរយៈពេល ១ (មួយ) ឆ្នាំ។ ក្នុងករណីចាំបាច់ **ក.ស.ជ.** អាចប្រជុំវិសាមញ្ញបានតាមការអញ្ជើញរបស់ប្រធាន។

**ក.ស.ជ.** ត្រូវធ្វើការបូកសរុបរបាយការណ៍ប្រចាំឆ្នាំអំពីលទ្ធផលនៃការអនុវត្តកម្មវិធីការងារ និងអនុសាសន៍ដែល **ក.ស.ជ.** ត្រូវដាក់ជូនរាជរដ្ឋាភិបាលតាមរយៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ប្រធាន **គ.ស.ជ.** ជាប្រធាននៃរាល់កិច្ចប្រជុំ។ ប្រសិនបើប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធាន។ **គ.ស.ជ.** អាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធឲ្យចូលរួមក្នុងអង្គប្រជុំបាន តែអ្នកជំនាញទាំងនោះមិនមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តទេ។

**មាត្រា៥.-**

**គ.ស.ជ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ននានា តំណាងអង្គការមិនមែនរដ្ឋាភិបាល តំណាងជនពិការដែលជាជនពិការ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍តាមការចាំបាច់។

**មាត្រា៦.-**

របៀបរបបនៃការប្រជុំរបស់ **គ.ស.ជ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ស.ជ.**។

**មាត្រា៧.-**

**គ.ស.ជ.** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន ដើម្បីបំពេញការងារ។

**មាត្រា៨.-**

**គ.ស.ជ.** មានលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិដែលមានទីតាំងនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា៩.-**

លេខាធិការដ្ឋាន **គ.ស.ជ.** ដឹកនាំដោយលេខាធិការមួយរូប ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ មន្ត្រីបម្រើការងារក្នុងលេខាធិការដ្ឋាន ជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ ដែលមានស្រាប់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ លេខាធិការដ្ឋាន **គ.ស.ជ.** អាចប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងទីប្រឹក្សាតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ស.ជ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា១០.-**

**គ.ស.ជ.** អាចបង្កើតគណៈកម្មការ ឬអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់។ សមាសភាពដឹកនាំរបស់គណៈកម្មការ ឬអនុគណៈកម្មការនីមួយៗ ត្រូវជ្រើសរើសពីសមាជិកនៃ **គ.ស.ជ.** និងដែលមានមន្ត្រីជំនាញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងជនពិការ តំណាងអង្គការជនពិការ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍចូលរួមជាសមាជិក។

សមាសភាព តួនាទីភារកិច្ចរបស់គណៈកម្មការ ឬអនុគណៈកម្មការជំនាញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ជ.**។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១១.-**

**ក.ស.ជ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ដោយឡែក ក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ក.ស.ជ.**មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀត សម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ